សេចក្តីព្រាង

រាជរដ្ឋាភិបាលកម្ពុជា

គោលនយោបាយ
រដ្ឋាភិបាលឌីជីថលកម្ពុជា
២០២២-២០៣៥

“កសាងរដ្ឋាភិបាលឌីជីថល ដើម្បីលើកកម្ពស់ គុណភាពជីវិតនិងទំនុកចិត្តប្រជាពលរដ្ឋ តាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ”

រៀបចំដោយ

ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

ខែមករា ឆ្នាំ២០២២

មាតិកា

បុព្វកថា i
អារម្ភកថា iii
ខ្លឹមសារសង្ខេប vii
បញ្ជីពាក្យកាត់ ix
១- សេចក្ដីផ្ដើម ១
២- ទស្សនាទានរដ្ឋាភិបាលឌីជីថល ២
២.១- និយមន័យ ២
២.២- គោលការណ៍អនុវត្ត ៣
២.៣- បច្ច័យវិជ្ជមាននៃរដ្ឋាភិបាលឌីជីថល ៤
២.៤- បទពិសោធនិងឧត្តមានុវត្តន៍រដ្ឋាភិបាលឌីជីថល ៥
៣- ស្ថានភាពរដ្ឋាភិបាលឌីជីថលកម្ពុជា ៨
៣.១- ដំណើរវិវត្ត ៨
៣.២- ការវិភាគរដ្ឋាភិបាលឌីជីថលកម្ពុជា ១១
៤- ចក្ខុវិស័យ ១៤
៥- គោលបំណង ១៤
៦- គោលដៅជាយុទ្ធសាស្ត្រ និងយុទ្ធសាស្ត្រ ១៤
៧- សកម្មភាពអាទិភាព ១៦
យុទ្ធសាស្ត្រទី១៖ ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល ១៦
យុទ្ធសាស្ត្រទី២៖ ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលសម្រាប់សេវាសាធារណៈ ... ១៧
យុទ្ធសាស្ត្រទី៣៖ ការរៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល ១៧
យុទ្ធសាស្ត្រទី៤៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសេវាប្រៃសណីយ៍ ១៨
យុទ្ធសាស្ត្រទី៥៖ ការរៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល ១៨
យុទ្ធសាស្ត្រទី៦៖ ការធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថលនិងសេវាសាធារណៈ ២១
យុទ្ធសាស្ត្រទី៧៖ ការកសាងមូលធនមនុស្សឌីជីថល ២៣
យុទ្ធសាស្ត្រទី៨៖ ការលើកកម្ពស់ការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល ២៥
យុទ្ធសាស្ត្រទី៩៖ ការរៀបចំកិច្ចសហការជាមួយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល ២៥
យុទ្ធសាស្ត្រទី១០៖ ការលើកកម្ពស់ធុរកិច្ចថ្មីឌីជីថល ២៦
៨- យន្តការដឹកនាំ សម្របសម្រួល អនុវត្ត តាមដាននិងវាយតម្លៃ ២៧

៨.១- យន្តការដឹកនាំ សម្របសម្រួល និងអនុវត្ត ២៧

៨.២- យន្តការតាមដាននិងវាយតម្លៃ ៣១

៩- ការបញ្ជៀស ការបន្ថយ និងដំណោះស្រាយផលប៉ះពាល់ និងការគ្រប់គ្រងហានិភ័យ ៣៣

៩.១- ការបញ្ជៀស ការបន្ថយ និងដំណោះស្រាយផលប៉ះពាល់ពាក់ព័ន្ធនឹងទិដ្ឋភាពសេដ្ឋកិច្ច និងសង្គម ៣៣

៩.២- ហានិភ័យពាក់ព័ន្ធនឹងការសម្របសម្រួលស្ថាប័ន ៣៣

៩.៣- ហានិភ័យពាក់ព័ន្ធនឹងការផ្លាស់ប្តូររបៀបរបបការងារ ៣៣

៩.៤- ហានិភ័យពាក់ព័ន្ធនឹងមូលធនមនុស្សនិងហិរញ្ញវត្ថុ ៣៤

៩.៥- ហានិភ័យពាក់ព័ន្ធនឹងការវិវឌ្ឍយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា ៣៤

៩.៦- ហានិភ័យពាក់ព័ន្ធនឹងសន្តិសុខឌីជីថលនិងការគ្រប់គ្រងក្នុងពេលប្រធានសក្តិ ៣៤

១០- សេចក្តីសន្និដ្ឋាន ៣៥

បរិសិដ្ឋ១ តារាងសកម្មភាពអាទិភាពនៃក្របខណ្ឌយុទ្ធសាស្ត្រដែលទទួលបន្ទុកដោយគណៈ-កម្មាធិការរដ្ឋាភិបាលឌីជីថល ៣៦

ឧបសម្ព័ន្ធ១ របាយការណ៍សិក្សាអំពីស្ថានភាពរដ្ឋាភិបាលឌីជីថលកម្ពុជា ៥០

ឧបសម្ព័ន្ធ២ សទ្ទានុក្រម ៨០

ខ្លឹមសារសង្ខេប

តាមការចង្អុលបង្ហាញក្នុង **ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥** ដោយផ្ដោតលើចក្ខុវិស័យកសាងសេដ្ឋកិច្ចនិងសង្គមឌីជីថលរស់រវើក ហើយដំណើរការនៃបរិវត្តកម្មឌីជីថលត្រូវបាននាំមុខដោយការកសាងរដ្ឋាភិបាលឌីជីថល ដែលជាសសរស្ដម្ភ សម្រាប់ជំរុញពលរដ្ឋនិងប្រជាពលរដ្ឋឱ្យចាប់យកបច្ចេកវិទ្យាឌីជីថលប្រកបដោយភាពជឿទុកចិត្ត។

បរិវត្តកម្មរដ្ឋាភិបាលឌីជីថលមានការរៀបចំស្របតាម*និន្នាការសកល*នៃបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤ ដោយផ្ដោតលើការពង្រឹងសេវាសាធារណៈ ដែលប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាឃ្នាស់។ កិច្ចការនេះគឺជារបៀបវារៈដ៏សំខាន់ក្នុងការជំរុញកំណែទម្រង់ក្រសួងស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅបង្កើតបរិយាកាសទាក់ទាញការវិនិយោគនិងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមប្រកបដោយបរិយាបន្ន។

វឌ្ឍនភាពនៃការកសាងរដ្ឋាភិបាលឌីជីថលកម្ពុជាស្ថិតនៅក្នុងដំណាក់កាលដំបូង ដោយហេតុថា ឌីជីថលនីយកម្មតាមក្រសួងស្ថាប័ននៅមិនទាន់បានធ្វើសមាហរណកម្មពេញលេញជាមួយគ្នានៅឡើយ។ ប្រព័ន្ធភាគច្រើនផ្ដោតសំខាន់លើការអភិវឌ្ឍកម្មវិធីសម្រាប់សម្រួលដល់ការងារ ដោយពុំមានយុទ្ធសាស្ត្រសម្រាប់បរិវត្តកម្មឌីជីថលរយៈពេលវែង និងពុំបានគិតគូរជាសំខាន់ពីប្រសិទ្ធភាពនិងប្រសិទ្ធផលដែលអាចកើតចេញពីទិន្នន័យប្រមូលផ្ដុំ។

នៅពេលនិន្នាការបរិវត្តកម្មឌីជីថលនិងនវានុវត្តន៍នៃបច្ចេកវិទ្យាឌីជីថលក្នុងពិភពលោក បន្តល្បឿនទៅមុខយ៉ាងឆាប់រហ័ស កម្ពុជាត្រូវរៀបចំខ្លួនជាស្រេចសម្រាប់ឆ្លើយតបនឹងការវិវត្តនេះ *ឱ្យទាន់ពេលវេលា* ដើម្បីទាញយកប្រយោជន៍ឱ្យអស់លទ្ធភាពពីការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលនិងឧស្សាហកម្មជំនាន់ទី៤។ យោងតាមការវិភាគអំពីភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង(SWOT)នៃស្ថានភាពរដ្ឋាភិបាលឌីជីថលកម្ពុជា ភាពខ្លាំងគឺ*ឆន្ទៈនយោបាយមោះមុត*របស់ប្រមុខរាជរដ្ឋាភិបាល។ ការគាំទ្រពីថ្នាក់ដឹកនាំកំពូលនឹងធ្វើឱ្យមានការសម្របសម្រួលជាធ្លុងមួយរវាងក្រសួងស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ វិស័យឯកជន សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍អន្តរជាតិ។

ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលកម្ពុជាបាននិងកំពុងជួបបញ្ហាប្រឈមជាច្រើន ដែលជាភាពខ្សោយនៃប្រព័ន្ធរដ្ឋាភិបាលឌីជីថល រួមមាន ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថលនៅមិនទាន់គ្របដណ្ដប់ពេញផ្ទៃប្រទេស បញ្ហាគុណភាពសេវា លទ្ធភាពធនធានហិរញ្ញវត្ថុ ប្រព័ន្ធឌីជីថលនៅតាមក្រសួងស្ថាប័នបង្កើតតាមតម្រូវការរៀងៗខ្លួននិងត្រួតគ្នា និងពុំមានប្រើប្រាស់ថ្នាលជាតិរួម។ ចំណុចខ្សោយផ្សេងទៀត មជ្ឈមណ្ឌលទិន្នន័យជាតិសម្រាប់ផ្ទុកទិន្នន័យរួមនិងផ្ដល់ធនធានគណនាពុំទាន់មាននៅឡើយ ចំណែកក្រសួងស្ថាប័នទាំងអស់ស្ទើរតែគ្មានហេដ្ឋារចនាសម្ព័ន្ធនិងសមត្ថភាពផ្នែកបច្ចេកទេសសន្តិសុខឌីជីថល។

ក្នុងដំណើរការនៃការធ្វើបរិវត្តកម្មឌីជីថល កាលានុវត្តភាពជាកត្តាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជាមានចំនួនយុវជនច្រើនធៀបនឹងប្រជាពលរដ្ឋទូទៅដែលងាយទទួលយកបច្ចេកវិទ្យាឌីជីថលបានឆាប់រហ័ស និងសន្ទុះកំណើននៃអ្នកប្រើប្រាស់អ៊ីនធឺណិត អាជីវកម្មប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងក្រុមហ៊ុនសេវាបច្ចេកវិទ្យាឌីជីថល។

ចក្ខុវិស័យនៃគោលនយោបាយនេះគឺ *កសាងរដ្ឋាភិបាលឌីជីថលដើម្បីលើកកម្ពស់គុណភាពជីវិតនិងទំនុកចិត្តប្រជាពលរដ្ឋ តាមរយៈការបម្រើសេវាសាធារណៈឱ្យកាន់តែល្អប្រសើរ*។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ ឯកសារគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ បានដាក់ចេញនូវយុទ្ធសាស្ត្រចំនួន១០ រួមមាន ***ទីមួយ*** ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ឌីជីថល ***ទីពីរ*** ការរៀបចំនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធទូទាត់សងប្រាក់ឌីជីថលសម្រាប់សេវាសាធារណៈ ***ទីបី*** ការរៀបចំនិងពង្រឹងហេដ្ឋារចនាសម្ព័ន្ធសន្តិសុខឌីជីថល ***ទីបួន*** ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសេវាប្រៃសណីយ៍ ***ទីប្រាំ*** ការរៀបចំអភិបាលកិច្ចរដ្ឋាភិបាលឌីជីថល ***ទីប្រាំមួយ*** ការធ្វើបរិវត្តកម្មរដ្ឋាភិបាលឌីជីថលនិងសេវាសាធារណៈ ***ទីប្រាំពីរ*** ការកសាងមូលធនមនុស្សឌីជីថល ***ទីប្រាំបី*** ការលើកកម្ពស់ការស្រាវជ្រាវនិងនវានុវត្តន៍ឌីជីថល

ទីប្រាំបួន ការរៀបចំកិច្ចសហការជាមួយក្រុមហ៊ុនបច្ចេកវិទ្យាឌីជីថល និង *ទីដប់* ការលើកកម្ពស់ធុរកិច្ចថ្មីឌីជីថល។ ក្រោមយុទ្ធសាស្ត្រទាំង១០ខាងលើនេះ មានសកម្មភាពអាទិភាពចំនួន៨៣ ដែលមានគម្រោងជាច្រើនថែមទៀត។

ដើម្បីអនុវត្តយុទ្ធសាស្ត្រនិងសកម្មភាពអាទិភាពខាងលើ *គណៈកម្មាធិការរដ្ឋាភិបាលឌីជីថល* ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ត្រូវបានបង្កើតឡើង និងមានតួនាទីដឹកនាំនិងសម្របសម្រួលក្រសួងស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងដំណើរការធ្វើបរិវត្តកម្មឌីជីថល ដោយមានការរៀបចំសេចក្តីណែនាំ ផែនការសកម្មភាព ការជំរុញការអនុវត្ត ការពិនិត្យ ការតាមដាន និងការវាយតម្លៃ ដើម្បីធានាបានប្រសិទ្ធភាព អន្តរប្រតិបត្តិការ និងសុវត្ថិភាពនៃប្រព័ន្ធព័ត៌មានឌីជីថលរបស់រាជរដ្ឋាភិបាលទាំងមូល។ ក្រោមការសម្របសម្រួលពីគណៈកម្មាធិការរដ្ឋាភិបាលឌីជីថល ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានតួនាទីស្នូលក្នុងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ដូចជា *ការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថលរួម ការគ្រប់គ្រងថ្នាលបច្ចេកវិទ្យារួម ការកំណត់ស្តង់ដាបច្ចេកទេស* សុសវែរ ហាដវែរ និងសន្តិសុខឌីជីថល និង *ការរៀបចំកម្មវិធីបណ្តុះបណ្តាល* ជំនាញឌីជីថល។ ជាមួយគ្នានេះ ក្រសួងស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវបង្កើត *អង្គភាពទទួលបន្ទុកបរិវត្តកម្មឌីជីថល* នៅតាមស្ថាប័នរបស់ខ្លួន ដែលមានតួនាទីជំរុញបរិវត្តកម្មឌីជីថល ក្នុងការចូលរួមអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថល។

ដើម្បីធានាបានតុល្យភាពរវាងការចំណាយនិងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល រាជរដ្ឋាភិបាលសម្រេចផ្តល់កញ្ចប់ថវិកាមួយ ស្របទៅនឹងបច្ច័យវិជ្ជមាននៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ដែលជាលទ្ធផលចុងក្រោយនៃការអនុវត្តគោលនយោបាយរដ្ឋាភិបាលឌីជីថល។ ក្នុងន័យខាងលើនេះ រាជរដ្ឋាភិបាលនឹងធ្វើវិភាជន៍ *ថវិកាអាទិភាពប្រចាំឆ្នាំ* និងត្រូវជ្រើសរើសបន្ថែម *មន្ត្រីជំនាញបច្ចេកវិទ្យាឌីជីថល* ក្នុងចំនួនសមស្របមួយ ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់ក្នុងការអនុវត្តសកម្មភាពអាទិភាពនៅក្នុងគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥។ ក្រៅពីថវិកាខាងលើ ក៏អាចមានថវិកាបន្ថែមដែលមានប្រភពពីវិស័យឯកជន ជំនួយឥតសំណង និង/ឬហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍។

គណៈកម្មាធិការរដ្ឋាភិបាលឌីជីថលមានភារកិច្ចរៀបចំយន្តការតាមដាននិងវាយតម្លៃការអនុវត្តសកម្មភាពអាទិភាព ដើម្បីធានាប្រសិទ្ធភាពនៃការប្រើប្រាស់ថវិកាលើការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល។ ជាមួយគ្នានេះ ការបញ្ចៀស ការកាត់បន្ថយ និងការដោះស្រាយផលប៉ះពាល់និងការគ្រប់គ្រងហានិភ័យពាក់ព័ន្ធនឹងទិដ្ឋភាពសេដ្ឋកិច្ចនិងសង្គម ត្រូវបានយកចិត្តទុកដាក់ តាមរយៈការសម្របសម្រួលក្រសួងស្ថាប័ន ការសម្រួលរបៀបរបបការងារ ការជ្រើសរើសបច្ចេកវិទ្យាឌីជីថល ការកៀរគរមូលធនមនុស្សនិងហិរញ្ញវត្ថុ ការការពារសន្តិសុខឌីជីថល និងការត្រៀមឆ្លើយតបទៅនឹងប្រធានសក្តិផ្សេងៗ។

ជារួម ការជ្រើសរើសសកម្មភាពអាទិភាពក្នុងការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល បានបង្ហាញនូវភាពប្រទាក់ក្រឡាគ្នា ជួយបំពេញគ្នាទៅវិញទៅមក ស៊ីជម្រៅ និងស្របតាមយុទ្ធសាស្ត្រច្បាស់លាស់ ទៅតាមគោលបំណងនិងគោលដៅជាក់លាក់ឆ្ពោះទៅរកការធ្វើបរិវត្តកម្មឌីជីថលពេញលេញ ដែលរាជរដ្ឋាភិបាលកម្ពុជាបានកំណត់សម្រាប់ឆ្នាំ២០៣៥។ បន្ថែមលើនេះ ការអនុវត្តសកម្មភាពអាទិភាពទាំងនោះនឹងធ្វើឡើងស្របតាមផែនការមេ ដោយមានផែនទីបង្ហាញផ្លូវច្បាស់លាស់ក្នុងឆន្ទៈនយោបាយដ៏មោះមុត សំដៅសម្រេចឱ្យបានជោគជ័យ ប្រសិទ្ធភាព និងប្រសិទ្ធផល។ រាល់សកម្មភាពអាទិភាពនីមួយៗនឹងត្រូវភ្ជាប់ជាមួយនូវសូចនាករវាស់វែងនិងកំណត់ដំណាក់កាលច្បាស់លាស់ ដោយមានក្រសួងស្ថាប័នទទួលបន្ទុកអនុវត្តលើសកម្មភាពអាទិភាពទាំងនោះ។ គួបផ្សំនឹងវិធានការដោះស្រាយទុកជាមុននូវផលប៉ះពាល់អវិជ្ជមានផ្សេងៗ និងការរៀបចំគ្រប់គ្រងហានិភ័យនានា ដែលអាចកើតមានឡើងក្នុងដំណើរការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ គឺជាឯកសារមួយដែលមានគុណភាពពេញលេញនិងគ្រប់គ្រាន់ សម្រាប់យកជាមគ្គុទេសក៍ក្នុងការអនុវត្ត ដើម្បីចូលរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល ដែលប្រជាពលរដ្ឋទទួលបានគុណភាពជីវិត និងភាពជឿទុកចិត្តលើរាជរដ្ឋាភិបាល។

បញ្ជីពាក្យកាត់

4G	ប្រព័ន្ធទូរសព្ទចល័តជំនាន់ទី៤ (4th Mobile Generation)
5G	ប្រព័ន្ធទូរសព្ទចល័តជំនាន់ទី៥ (5th Mobile Generation)
AI	បញ្ញាសិប្បនិម្មិត (Artificial Intelligence)
AAE-1	ខ្សែកាបក្រោមបាតសមុទ្រអាស៊ី-អាហ្វ្រិក-អឺរ៉ុប (Asia-Africa-Europe 1)
BPR	ការរៀបចំដំណើរការការងារឡើងវិញ (Business Process Re-engineering)
CA	វិញ្ញាតធរហត្ថលេខាឌីជីថល (Certificate Authority)
CamDX	ថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (Cambodia Data Exchange)
CADT	បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (Cambodia Academy of Digital Technology)
EGDI	សន្ទស្សន៍អភិវឌ្ឍរដ្ឋាភិបាលឌីជីថល (E-Government Development Index)
e-Government	រដ្ឋាភិបាលអេឡិចត្រូនិក (Electronic Government)
G2G	ការបម្រើសេវាពីរដ្ឋាភិបាលទៅរដ្ឋាភិបាល (Government to Government)
G4C	ការបម្រើសេវាសាធារណៈពីរដ្ឋាភិបាលដើម្បីប្រជាពលរដ្ឋ (Government for Citizen)
G2B	ការបម្រើសេវាសាធារណៈពីរដ្ឋាភិបាលទៅធុរកិច្ច (Government to Business)
GDP	ផលិតផលក្នុងស្រុកសរុប (Gross Domestic Product)
KYC	ប្រព័ន្ធកំណត់អត្តសញ្ញាណអតិថិជន (Know Your Customer)
MCT	ខ្សែកាបក្រោមបាតសមុទ្រម៉ាឡេស៊ី កម្ពុជា ថៃ (Malaysia Cambodia Thailand)
NiDA	អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការអភិវឌ្ឍន៍វិស័យបច្ចេកវិទ្យាគមនាគមន៍ព័ត៌មានវិទ្យា (National Information Communication Technology Development Authority)
NIPTICT	វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (National Institute of Posts, Telecommunications and Information Communication and Technology)
PKI	ហេដ្ឋារចនាសម្ព័ន្ធគន្លឹះសាធារណៈ (Public Key Infrastructure)
RCEP	ភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់ (Regional Comprehensive Economic Partnership)
Root CA	វិញ្ញាតធរហត្ថលេខាឌីជីថលមេ (Root Certificate Authority)

SWOT	ភាពខ្លាំង ភាពខ្សោយ កាលានុវត្តភាព និងការគំរាមកំហែង (Strengths, Weaknesses, Opportunities, and Threats)
UN-DESA	នាយកដ្ឋានសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិ United Nations Department of Economic and Social Affairs

១- សេចក្តីផ្តើម

ស្របតាមនិន្នាការពិភពលោក ការកសាងរដ្ឋាភិបាលឌីជីថលគឺជារបៀបវារៈដ៏សំខាន់ក្នុងការជំរុញកំណែទម្រង់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ និងការបង្កើតបរិយាកាសអំណោយផលដល់ការជំរុញការវិនិយោគនិងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមប្រកបដោយបរិយាបន្ន។ និន្នាការនៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលមានការវិវត្តប្រសើរឡើងជាលំដាប់នៅគ្រប់តំបន់ក្នុងពិភពលោក។ លទ្ធផលនៃការវាយតម្លៃការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលដោយនាយកដ្ឋានសេដ្ឋកិច្ចនិងសង្គមនៃអង្គការសហប្រជាជាតិ(UN-DESA) បានបង្ហាញថា តម្លៃមធ្យមនៃសន្ទស្សន៍អភិវឌ្ឍរដ្ឋាភិបាលឌីជីថលបានកើនឡើងពី០,៥៥ក្នុងឆ្នាំ២០១៨ ដល់០,៦០ក្នុងឆ្នាំ២០២០ នៅប្រទេសចំនួន១២៦ ក្នុងចំណោម១៩៣ប្រទេស។ ក្នុងបរិបទតំបន់ ការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលត្រូវបានកំណត់ជាគោលដៅអាទិភាពសំខាន់ក្នុងផែនការមេឌីជីថលអាស៊ានឆ្នាំ២០២៥ ជាមូលដ្ឋានក្នុងការបម្រើសេវាសាធារណៈឌីជីថល ដែលមានគុណភាពខ្ពស់និងឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋនៃប្រទេសក្នុងតំបន់។

តាមការចង្អុលបង្ហាញ ក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ការកសាងរដ្ឋាភិបាលឌីជីថល ជាសសរស្តម្ភចាំបាច់ និងត្រូវបោះជំហានមុន ដើម្បីជំរុញល្បឿនក្នុងការកសាងពលរដ្ឋនិងធុរកិច្ចឌីជីថល និងធានាភាពជោគជ័យខ្ពស់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថលទាំងមូល។ រដ្ឋាភិបាលឌីជីថលគឺជាការរៀបចំប្រព័ន្ធអភិបាលកិច្ច ការកែលម្អនិងការលើកកម្ពស់ប្រសិទ្ធភាពក្នុងការបម្រើសេវាសាធារណៈ តាមរយៈការធ្វើបរិវត្តកម្មឌីជីថលរបស់ក្រសួងស្ថាប័នលើការគ្រប់គ្រងនិងរចនាសម្ព័ន្ធ ដែលនាំឱ្យប្រជាពលរដ្ឋនិងធុរកិច្ចចាប់យកនិងប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីបង្កើនប្រសិទ្ធភាព ប្រសិទ្ធផល តម្លាភាព ការបើកចំហ ក៏ដូចជាជំរុញសន្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។

នាពេលបច្ចុប្បន្ន ប្រព័ន្ធព័ត៌មានឌីជីថលនិងការគ្រប់គ្រងទិន្នន័យដែលត្រូវបានអភិវឌ្ឍនៅតាមក្រសួងស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិ មានលក្ខណៈដាច់ដោយឡែកពីគ្នាឬច្រំដែល ទោះស្ថិតក្រោមស្ថាប័នតែមួយឬរវាងស្ថាប័នផ្សេងគ្នាក៏ដោយ។ ទោះបីជាក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍មានមជ្ឈមណ្ឌលទិន្នន័យជាតិ ក៏បញ្ហាប្រឈមខាងលើនេះ នៅមិនទាន់បានដោះស្រាយនៅឡើយ។ នៅតាមក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ មានកង្វះខាតនូវការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ភាពជាម្ចាស់លើប្រព័ន្ធដែលមានស្រាប់ ការការពារសន្តិសុខឌីជីថល មូលធនមនុស្សលើបច្ចេកវិទ្យាឌីជីថល និងការប្រតិបត្តិនិងការថែទាំជាប្រចាំ សម្រាប់អភិវឌ្ឍនិងគាំទ្រដល់ប្រព័ន្ធព័ត៌មានឌីជីថលនិងការគ្រប់គ្រងទិន្នន័យ។ ការអភិវឌ្ឍប្រព័ន្ធនានាពុំមានការធ្វើផែនការនិងការផ្តល់ហិរញ្ញប្បទានជាលក្ខណៈប្រព័ន្ធដែលធ្វើឱ្យការអភិវឌ្ឍប្រព័ន្ធព័ត៌មានឌីជីថលនិងការគ្រប់គ្រងទិន្នន័យមួយចំនួនមានភាពយឺតយ៉ាវ ឬត្រូវបានផ្អាកក្រោយពីដំណើរការមួយរយៈ។

ដូចនេះ ការរៀបចំគោលនយោបាយរដ្ឋាភិបាលឌីជីថលគឺជាការចាំបាច់និងបន្ទាន់ សំដៅដោះស្រាយបញ្ហាប្រព័ន្ធព័ត៌មានឌីជីថល ហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ អភិបាលកិច្ចទិន្នន័យ និងមូលធនមនុស្ស ដើម្បីជំរុញបរិវត្តកម្មឌីជីថលក្នុងវិស័យសេដ្ឋកិច្ចនិងសង្គមឱ្យមានភាពស៊ីសង្វាក់គ្នា។ រាជរដ្ឋាភិបាលកម្ពុជាដាក់ចេញនូវគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ ដោយមិនរាប់បញ្ចូលសកម្មភាពអាទិភាពមួយចំនួនដែលបែងចែកទៅគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថលនិងគណៈកម្មាធិការសន្តិសុខឌីជីថល ដើម្បីបំពេញលើឯកសារក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ដែលជាផែនទីមេទាំងមូល។ ឯកសារនេះរៀបចំឡើងដោយចែកជាផ្នែកគោលនយោបាយដែលជាឯកសារគោល បរិសិដ្ឋដែលជាឯកសារភ្ជាប់ និងឧបសម្ព័ន្ធដែលជាឯកសារយោង។

២- ទស្សនាទានរដ្ឋាភិបាលឌីជីថល

២.១- និយមន័យ

នៅក្នុងយុគសម័យឌីជីថល ការរីកចម្រើនឥតឈប់ឈរនៃបច្ចេកវិទ្យាឌីជីថលដែលមានជាអាទិ៍ កុំព្យូទ័រ អ៊ីនធឺណិត បច្ចេកវិទ្យាចល័ត ឧបករណ៍ឌីជីថលចល័ត និងបច្ចេកវិទ្យាសម្រាប់ការវិភាគទិន្នន័យ បាននិងកំពុងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ បច្ចេកវិទ្យាឌីជីថលនេះបានធ្វើឱ្យមានការផ្លាស់ប្ដូររបៀបរស់នៅប្រចាំថ្ងៃនិងបានជំរុញឱ្យរដ្ឋាភិបាលនានាធ្វើការផ្លាស់ប្ដូររបៀបបម្រើសេវា ការប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋនិងធុរកិច្ច ពីតាមបែបប្រពៃណីមកកាន់បែបទំនើប ដែលហៅថា *រដ្ឋាភិបាលឌីជីថល* ។ ក្នុងន័យនេះ រដ្ឋាភិបាលឌីជីថលត្រូវផ្ដោតលើការធ្វើទំនើបកម្មនិងសមាហរណកម្មប្រព័ន្ធគ្រប់គ្រងរដ្ឋាភិបាលនិងសេវាសាធារណៈ ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ និងបម្រើសេវាសាធារណៈឆ្លើយតបនឹងតម្រូវការប្រជាពលរដ្ឋ ដោយយុត្តិធម៌ សមធម៌ ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាបន្ន។

ដំណើរការនៃរដ្ឋាភិបាលឌីជីថលត្រូវឈរលើប្រព័ន្ធអភិបាលកិច្ចឯកភាព (Whole-of-government Approach) ដែលគ្រប់ក្រសួងស្ថាប័នទាំងអស់ជាផ្នែកមួយនិងធ្វើអន្តរសកម្មទៅវិញទៅមកក្នុងប្រព័ន្ធនេះ។ ក្រសួងស្ថាប័ននីមួយៗអាចរៀបចំនិងអភិវឌ្ឍប្រព័ន្ធព័ត៌មានឌីជីថលសម្រាប់បម្រើសេវាផ្ទៃក្នុងនិងសេវាសាធារណៈរបស់ខ្លួន ដោយត្រូវតភ្ជាប់គ្នា ចែករំលែកទិន្នន័យ និងបំពេញមុខងារជាប្រព័ន្ធរដ្ឋាភិបាលឌីជីថលតែមួយ។

ជាទូទៅ ការកសាងរដ្ឋាភិបាលឌីជីថលត្រូវបានបែងចែកជា៥កម្រិត ដូចខាងក្រោម៖

- **កម្រិតទី១** : រដ្ឋាភិបាលអេឡិចត្រូនិក(e-Government) ជាដំណាក់កាលដំបូងនៃរដ្ឋាភិបាលឌីជីថល ដោយមានការអភិវឌ្ឍនិងការប្រើប្រាស់ប្រព័ន្ធព័ត៌មានឌីជីថល ដើម្បីផ្ដល់ព័ត៌មាននិងសេវាតាមអនឡាញ ប៉ុន្តែប្រព័ន្ធព័ត៌មានឌីជីថល ហេដ្ឋារចនាសម្ព័ន្ធ និងទិន្នន័យមានសភាពដាច់ដោយឡែកនិងមិនទាន់បានធ្វើសមាហរណកម្មចូលគ្នា។
- **កម្រិតទី២** : រដ្ឋាភិបាលបើកចំហ(Open Government) ជាដំណាក់កាលដែលប្រព័ន្ធព័ត៌មានឌីជីថលត្រូវបានបង្កើតឡើងដើម្បីទទួលមតិយោបល់ពីប្រជាពលរដ្ឋនិងមានអន្តរសកម្មជាមួយអ្នកទទួលសេវា។ នៅក្នុងកម្រិតទី២ ព័ត៌មានរបស់រដ្ឋាភិបាលត្រូវបានបើកចំហដល់សាធារណជន ដើម្បីធានាតម្លាភាពនិងគណនេយ្យភាព។
- **កម្រិតទី៣** : រដ្ឋាភិបាលផ្ដោតលើទិន្នន័យ(Data-centric Government) ជាការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល ដែលចាត់ទុកទិន្នន័យជាទ្រព្យសំខាន់និងចាំបាច់។ ការអភិវឌ្ឍកម្មវិធីមិនមែនជាចំណុចអាទិភាពតទៅទៀតផ្ទុយទៅវិញ ការប្រមូល ការប្រើប្រាស់ និងការវិភាគទិន្នន័យគឺជាអាទិភាពរបស់រដ្ឋាភិបាល។ ប្រព័ន្ធព័ត៌មានឌីជីថល ហេដ្ឋារចនាសម្ព័ន្ធ និងទិន្នន័យរបស់ក្រសួងស្ថាប័នថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានធ្វើសមាហរណកម្មជាបណ្ដើរៗ ដោយប្រើប្រាស់ថ្នាលឌីជីថលរួមរបស់រដ្ឋាភិបាល(Government as a Platform)សម្រាប់ដំណើរការការងារ។
- **កម្រិតទី៤** : រដ្ឋាភិបាលបរិវត្តកម្មពេញលេញ(Fully Transformed Government) ជាដំណាក់កាលដែលក្រសួងស្ថាប័នធ្វើបរិវត្តកម្មឌីជីថលពេញលេញ ដោយប្រព័ន្ធព័ត៌មានឌីជីថល ហេដ្ឋារចនាសម្ព័ន្ធ និងទិន្នន័យទាំងអស់ត្រូវបានធ្វើសមាហរណកម្មចូលគ្នា ហើយការប្រើប្រាស់ ការគ្រប់គ្រង ការការពារទិន្នន័យ និងការបម្រើសេវាមានលក្ខណៈល្អប្រសើរ។
- **កម្រិតទី៥** : រដ្ឋាភិបាលឆ្លាត(Smart Government) ជាដំណាក់កាលដែលការប្រមូលនិងការវិភាគទិន្នន័យត្រូវបានធ្វើឡើងដោយស្វ័យប្រវត្តិ សម្រាប់ជាមូលដ្ឋានដល់ការសម្រេចចិត្តនិងការឆ្លើយតបនឹងបញ្ហា។ នវានុវត្តន៍នៃសេវារដ្ឋាភិបាលឌីជីថល ដោយប្រើប្រាស់បច្ចេកវិទ្យាថ្មីៗមានជាអាទិ៍ បញ្ញាសិប្បនិម្មិត អ៊ីនធឺណិតនៃវត្ថុ ទិន្នន័យធំប្លុកឆេន បច្ចេកវិទ្យាក្លោដ អាចកើតមានឡើងពេញលេញនៅក្នុងដំណាក់កាលនេះ។